# កម្រងសំនួរសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការងារតាមដានសង្កេតសុខភាពសត្វព្រៃ

សម្រាប់ឆ្មាំព្រៃ (ឆ្មាំព្រៃ) ឬមន្ត្រីមានតួនាទីចុះតាមដានផ្សេងៗទៀត

ផ្នែកទី ១៖ ចំណេះដឹងអំពីសុខភាពសត្វព្រៃ

ឆ្មាំព្រៃមានសមត្ថភាព៖

**1.1 យល់ដឹងអំពីគោលគំនិតជាមូលដ្ឋានអំពីសុខភាពសត្វព្រៃ ព្រមទាំងទំនាក់ទំនងរវាងសុខភាពសត្វព្រៃ ទៅនឹងសុខភាពរបស់សត្វចិញ្ចឹម ក៏ដូចជាសុខភាពរបស់ខ្លួនពួកគេផ្ទាល់ផងដែរ ។**

ដូចម្តេចដែលហៅថា ជម្ងឺហ្សូណូទិក (zoonotic disease)?

ក) គឺជាជម្ងឺដែលអាចឆ្លងរាលដាលពីសត្វទៅមនុស្ស

ខ) គឺជាជម្ងឺដែលមានតែនៅលើសត្វដែលរស់នៅក្នុងសួនសត្វ

គ) គឺជាជម្ងឺដែលអាចឆ្លងពីសត្វព្រៃមកសត្វស្រុក ប៉ុន្តែមិនអាចឆ្លងមកមនុស្សបានទេ

សត្វអាចស្លាប់ដោយសារតែ៖

ក) ជម្ងឺឆ្លង

ខ) ថ្នាំបំពុល

គ) ការប្រម៉ាញ់

ឃ) របួស

ង) មូលហេតុទាំងអស់ខាងលើនេះ

**1.2 យល់ដឹងអំពីតួនាទីដែលខ្លួនត្រូវបំពេញក្នុងការងារតាមដានសង្កេតសុខភាពសត្វព្រៃ**

តើឆ្មាំព្រៃអាចធ្វើយ៉ាងណាខ្លះដើម្បីជួយដល់ការងារតាមដានសង្កេតសុខភាពសត្វព្រៃ?

ក) ស្វែងរក ឬជួបប្រទះ រួចរាយការណ៍អំពីករណីសត្វព្រៃងាប់ខុសប្រក្រតី

ខ) ជួយប្រមូលទិន្នន័យជាមូលដ្ឋានសម្រាប់បម្រើដល់ការងារតាមដានសង្កេតសុខភាពសត្វព្រៃ

គ) ទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺទៅលើសត្វស្រុក និងមនុស្ស

ឃ) ការងារទាំងអស់ខាងលើ

**1.3 យល់ដឹងថាតើមាន ប៉ាតូហ្សែន អ្វីខ្លះ និងមូលហេតុចំបងៗដែលបណ្តាលឲ្យជម្ងឺឆ្លងរីករាលដាល**

តើ ប៉ាតូហ្សែននៃជម្ងឺហ្សូណូទិក អាចឆ្លងពីសត្វព្រៃទៅមនុស្សដោយរបៀបណា?

ក) ដោយសារការទទួលទានសត្វព្រៃ

ខ) ដោយសារសត្វព្រៃខាំ

គ) ស្រូបមេរោគពីសត្វឈឺតាមរយៈការដកដង្ហើម ឬហិត

ឃ) ដោយសារមូលហេតុទាំងអស់ខាងលើនេះ

ផ្នែកទី ២៖ ការសិក្សាវាយតម្លៃ និងវិភាគអំពីហេតុការណ៍អ្វីមួយ

ផ្ទាំព្រមានសមត្ថភាព៖

2.1. ចេះពីរបៀបវាយតម្លៃអំពីស្ថានភាពដែលមានសត្វព្រៃងាប់ រួចកំណត់ថាតើទីកន្លែងនោះមានសុវត្ថិភាពអាចចូលទៅត្រួតពិនិត្យ និងស៊ើបអង្កេតលម្អិតបានដែរឬយ៉ាងណា ។

តើសញ្ញាទូទៅដែលគេអាចសម្គាល់បានថាសត្វងាប់ដោយសារជម្ងឺមានអ្វីខ្លះ?

ក)មានឈាមខ្មៅកកនៅតាមមាត់ ច្រមុះ និងរន្ធគូថ

ខ) ហើម

គ) មានសត្វងាប់លើពីមួយនៅក្នុងតំបន់តែមួយដូចគ្នា

ឃ) គ្រប់ចំណុចទាំងអស់ខាងលើ

បើអ្នកសង្ស័យថាសត្វមានជម្ងឺ អ្នកត្រូវរាយការណ៍ជាបន្ទាន់ភ្លាមទៅថ្នាក់លើរបស់អ្នក ។ អ្នកមិនត្រូវអនុញ្ញាតឲ្យប៉ះពាល់សាកសពសត្វឡើយព្រោះ៖

ក) ការប៉ះពាល់សត្វព្រៃគឺជាទង្វើរខុសច្បាប់

ខ) អ្នកអាចឆ្លងជម្ងឺពីសត្វនោះ

គ) ពុំមានមូលហេតុត្រូវប៉ះឡើយ

ឃ) ចម្លើយ ក និង ខ

បើអ្នកសង្ស័យសត្វមានជម្ងឺ អ្នកត្រូវធ្វើយ៉ាងណា?

ក) ត្រូវបំពេញទម្រង់របាយការណ៍ និងយកសំណាក

ខ) មិនត្រូវប៉ះពាល់សាកសពឡើយ ប៉ុន្តែត្រូវថតសាកសពឲ្យច្បាស់ដើម្បីយកព័ត៌មានលម្អិត

គ) មិនត្រូវចូលជិតសាកសពឡើយ និងត្រូវរាយការណ៍ទៅថ្នាក់លើរបស់អ្នក

ឃ) មិនចាំបាច់ត្រូវធ្វើអ្វីទាំងអស់

2.2. បំពេញឯកសារ និងចងក្រងព័ត៌មានឲ្យបានសុក្រិតបំផុតអំពីទិដ្ឋភាព និងសត្វ ។

តើក្នុងចំណោមព័ត៌មានខាងក្រោមនេះ មួយណាដែលចាត់ទុកថាជាព័ត៌មានដែលសំខាន់ត្រូវយកនៅពេលអ្នកជួបប្រទះខ្មោចសត្វព្រៃងាប់?

ក) រូបថត

ខ) ទិន្នន័យអំពីទីតាំង (GPS)

គ) ក & ខ

ឃ) ពុំមានត្រូវការព័ត៌មានអ្វីឡើយ

ក្រៅពីកត់ត្រាអំពីចំនួនសត្វ និងឈ្មោះសត្វ អ្នកក៏ត្រូវប្រមូលព័ត៌មានផ្សេងទៀតដូចខាងក្រោម៖

ក) សញ្ញាគួរឲ្យកត់សំគាល់នានាដែលមាននៅលើសត្វ

ខ) របាយការណ៍អំពីសត្វស្រុក ឬមនុស្ស ដែលឈឺ ឬស្លាប់នៅក្នុងតំបន់នោះ

គ) អាកាសធាតុ

ឃ) ក & ខ

ង) ក ខ & គ

ផ្នែកទី ៣៖ របៀបថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួន

ផ្ទាំព្រមានសមត្ថភាព៖

3.1. យល់ដឹងថាអ្នកណាដែលត្រូវស្លៀកពាក់សម្លៀកបំពាក់ការពារខ្លួន (PPE) នៅពេលយកសំណាកសត្វ ។

តើអ្នកណាដែលត្រូវស្លៀកសម្លៀកបំពាក់ PPE នៅពេលយកសំណាកសត្វព្រៃនៅក្នុងព្រៃ?

ក) គឺអ្នកដែលត្រូវប៉ះពាល់សាកសពសត្វប៉ុណ្ណោះ

ខ) គឺអ្នកដែលត្រូវប៉ះពាល់សាកសពសត្វ និងអ្នកដែលជួយបិទស្លាក សរសេរស្លាកនៅលើបំពង់រក្សាសំណាក....។ល។

គ) គឺអ្នកទាំងឡាយណាដែលត្រូវចូលទៅជិតសាកសពសត្វ

ឃ) គឺអ្នកថតរូប

3.2. យល់ដឹងថាហេតុអ្វីបានជាគេចាំបាច់ត្រូវពាក់ម៉ាស់ អៀម ស្រោមដៃ វ៉ែនតាការពារការឆ្លងជម្ងឺពីសត្វ និងប្រតពមេរោគ ។

តើក្នុងចំណោមសម្ភារៈខាងក្រោមនេះ សម្ភារៈណាមួយដែលជាសម្ភារៈ PPE? សូមជ្រើសរើសគ្រប់ចំណុចទាំងអស់ដែលយល់ថាត្រឹមត្រូវ៖

□ ម៉ាស់

□ ថ្នាំបាញ់សត្វល្អិត

□ ស្រោមដៃ

□ វ៉ែនតា

□ ស្បែងអៀម

ហេតុអ្វីចាំបាច់ពាក់ម៉ាស់នៅពេលយកសំណាក?

ក) ដើម្បីការពារកុំឲ្យមានគ្រោះថ្នាក់ដល់មុខ

ខ) ដើម្បីការពារកុំឲ្យឆ្លងជម្ងឺតាមដង្ហើម (ដោយសារដកដង្ហើមស្រូបចូល) ពីប្រភពមេរោគ

គ) ដើម្បីកុំឲ្យគេស្គាល់មុខអ្នកនៅពេលថតរូប

ឃ) គ្រប់ចម្លើយទាំងអស់ខាងលើ

ហេតុអ្វីចាំបាច់ត្រូវពាក់ស្រោមដៃនៅពេលយកសំណាកពីសត្វមានជីវិត?

ក) ដើម្បីការពារកុំឲ្យឆ្លងជម្ងឺពីប្រភពមេរោគ តាមរយៈការប៉ះពាល់ដោយផ្ទាល់របស់អ្នកចំពោះសត្វនោះ

ខ) ដើម្បីការពារកុំឲ្យឆ្លងជម្ងឺពីប្រភពមេរោគ តាមរយៈការប៉ះពាល់ដោយផ្ទាល់ពីសត្វមកលើអ្នក

គ) ទាំងចម្លើយ ក & ខ

ហេតុអ្វីចាំបាច់ត្រូវពាក់ស្រោមដៃនៅពេលយកសំណាកពីសត្វងាប់?

ក) ដើម្បីការពារកុំឲ្យសាកសពសត្វនោះឆ្លងមេរោគដែលនៅជាប់នឹងស្បែករបស់អ្នក

ខ) ដើម្បីការពារកុំឲ្យឆ្លងមេរោគពីសត្វមកលើអ្នក តាមរយៈការប៉ះពាល់ដោយផ្ទាល់

គ) ទាំងចម្លើយ ក & ខ

### 3.3 របៀបស្លៀកពាក់ និងដោះសម្លៀកបំពាក់ PPE ឲ្យបានត្រឹមត្រូវ និងតាមលំដាប់លំដោយ ។

បើសិនជាជួបប្រទះសត្វងាប់ តើអ្នកត្រូវស្លៀកសម្លៀកបំពាក់ PPE នៅពេលណា?

ក) មុនពេលចូលទៅកាន់ទីកន្លែងដែលមានសត្វព្រៃឈឺ ឬងាប់

ខ) ក្រោយពេលអ្នកបានចូលទៅជិតដើម្បីមើល និងថតរូបសត្វរួចហើយ

គ) យើងត្រូវការប្រើប្រាស់ PPE តែពេលណាត្រូវធ្វើការជិតសត្វរស់ និងងាប់ប៉ុណ្ណោះ ។ នៅពេលយកសំណាកសាកសពសត្វ យើងមិនចាំបាច់ពាក់ទេ ។

### 3.4 របៀបបោះចោលឲ្យបានត្រឹមត្រូវនូវសម្លៀកបំពាក់ PPE ដែលប្រឡាក់ប្រឡូក ។

តើអ្នកគួរបោះចោលសម្លៀកបំពាក់ PPE ដែលអ្នកប្រើប្រាស់រួចដោយរបៀបណា? **និយាយឲ្យចំទៅតាមទម្លាប់របស់ប្រទេស*

ក) គរវាទុកនៅលើដីនៅនឹងកន្លែង/ក្នុងព្រៃ

ខ) ដាក់ចូលក្នុងកាតាបយកត្រឡប់មកវិញ

គ) ដុត ឬកប់សម្ភារៈ PPE នៅនឹងកន្លែង

ឃ) ចម្លើយ ខ & គ

បន្ទាប់ពីយកសំណាកសាកសពសត្វរួចហើយ អ្នកត្រូវទុកសម្លៀកបំពាក់ PPE របស់អ្នកនៅនឹងកន្លែង៖

- ត្រឹមត្រូវ
- មិនត្រឹមត្រូវ

ផ្នែកទី ៤៖ ការអនុវត្តតាមគោលការណ៍

ផ្ទាំព្រៃមានសមត្ថភាព៖

4.1. រាយការណ៍អំពីហេតុការណ៍ដែលមានករណីសត្វព្រៃ ឈឺ/ងាប់ ទៅកាន់មន្ត្រីទទួលបន្ទុកដោយអនុលោមតាមគោលការណ៍ក្រមប្រតិបត្តិស្តង់ដា (SOP) សម្រាប់ការតាមដានសុខភាពសត្វព្រៃ (ឬគោលការណ៍ណែនាំផ្សេងៗទៀត) ។

4.2. រាយការណ៍អំពីហេតុការណ៍ដែលមានករណីសត្វព្រៃ ឈឺ/ងាប់ ជាបន្ទាន់ភ្លាម បើសិនមានសញ្ញាបញ្ជាក់ថាករណីនោះជាករណីបន្ទាន់ (ដូចជាមានសត្វងាប់លើសពីមួយនៅក្នុងកន្លែងតែមួយដូចគ្នា)

**ដំបូង** តើអ្នកគួរធ្វើអ្វីមុន បើអ្នកជួបប្រទះសត្វបក្សីមួយឈឺ និងសត្វបក្សីបីក្បាលទៀតងាប់នៅក្នុងកន្លែងតែមួយដោយពុំដឹងមូលហេតុ?

ក) ត្រូវរាយការណ៍ជាបន្ទាន់ ទៅថ្នាក់លើ និងអាជ្ញាធរដែនដីដែលមានសមត្ថកិច្ច

ខ) យកសំណាកភ្លាមពីសត្វទាំងអស់ដែលបានឃើញក្នុងទីតាំងនោះ

គ) ត្រូវធ្វើការពិនិត្យអង្កេតតំបន់នោះឲ្យគ្រប់ជ្រុងជ្រោយមុននឹងសម្រេចថាគួរធ្វើយ៉ាងណាជាបន្តទៀត

ឃ) យកសត្វដែលឈឺត្រឡប់មកប៉ុស្តិ៍យាមវិញ

ផ្នែកទី ៥៖ ការយកសំណាក ការរក្សាទុក និងដឹកជញ្ជូន

ផ្ទាំព្រៃមានសមត្ថភាព៖

5.1. កំណត់ដឹងថាតើស្ថានភាពបែបណាដែលត្រូវយកសំណាក ។

តើពេលណាទើបអ្នកគួរយកសំណាក?

ក) ពេលអ្នកជួបប្រទះសត្វងាប់ដោយពុំដឹងមូលហេតុច្បាស់លាស់

ខ) ពេលអ្នកជួបប្រទះសត្វងាប់ និងមានសុវត្ថិភាពអាចយកសំណាកបាន

គ) ពេលអ្នកជួបប្រទះសត្វងាប់ដោយសារការប្រម៉ាញ់ ឬជាប់អន្ទាក់

ឃ) ពេលអ្នកជួបប្រទះសត្វងាប់ និងសង្ស័យថាអាចមានថ្នាំពុល

ង) ចម្លើយទាំងអស់ខាងលើ

តើពេលណាទើបអ្នកគួរយកសំណាក?**

ក) ពេលអ្នកជួបប្រទះសត្វងាប់ដោយពុំដឹងមូលហេតុច្បាស់លាស់

ខ) ពេលអ្នកជួបប្រទះសត្វងាប់ដោយសារការប្រម៉ាញ់ ឬជាប់អន្ទាក់

គ) ពេលអ្នកជួបប្រទះសត្វងាប់ និងសង្ស័យថាអាចមានថ្នាំពុល

ឃ) ចម្លើយទាំងអស់ខាងលើ

** *បើប្រទេសណាមួយពុំបានណែនាំឲ្យផ្ទាំព្រៃយកសំណាកពីសត្វរស់ទេ សូមប្រើសំនួរនេះជំនួសវិញ*

5.2. របៀបយកសំណាកតាមមាត់ឲ្យបានត្រឹមត្រូវ និងមិនឲ្យសំឡីត្បារយកសំណាកនោះប្រឡូកប្រឡាក់

នៅពេលអ្នកយកសំណាកដោយប្រើសំឡីត្បារ តើអ្នកត្រូវប្រុងប្រយ័ត្នទៅលើអ្វី?

ក) ត្រូវជៀសវាងយកដៃទៅប៉ះពាល់ចុងសំឡី

ខ) ត្រូវជៀសវាងកុំឲ្យចុងសំឡីប៉ះដី

គ) មិនត្រូវឲ្យសំឡីដែលបានត្បាររួចហើយនោះត្រូវខ្យល់ឡើយ

ឃ) ចម្លើយ ក & ខ

5.3. របៀបយកសំណាកតាមរន្ធច្រមុះ/រន្ធគូថឲ្យបានត្រឹមត្រូវ និងមិនឲ្យសំឡីត្បារយកសំណាកនោះប្រឡូកប្រឡាក់

អ្នកគួរប្រើប្រាស់សំឡីត្បារដដែលសម្រាប់យកសំណាកទាំងតាមមាត់ និងរន្ធគូថ

- ត្រឹមត្រូវ
- មិនត្រឹមត្រូវ

5.4. របៀបយកសំណាកពីលាមកឲ្យបានត្រឹមត្រូវ

5.5. របៀបសរសេរស្លាកលើសំណាកឲ្យបានត្រឹមត្រូវ

5.6. របៀបវេចខ្ចប់សំណាកឲ្យបានត្រឹមត្រូវ និងប្រកបដោយសុវត្ថិភាព

ក្នុងកញ្ចប់យកសំណាករបស់យើងមួយ តើយើងអាចយកសាកសពសត្វចំនួនប៉ុន្មាន?

ក) ១

ខ) ២

គ) ៥

ឃ) ចម្លើយ ក និង ខ សុទ្ធតែត្រឹមត្រូវ

5.7. របៀបច្រកសាកសពសត្វទាំងមូលឲ្យបានត្រឹមត្រូវ (ដោយមានទាំងទម្រង់របាយការណ៍អំពីសត្វឈឺ/ងាប់) និងប្រកបដោយសុវត្ថិភាព ។

តើត្រូវទុកទម្រង់របាយការណ៍អំពីសត្វឈឺ/ងាប់កន្លែងណា?

ក) ក្នុងថង់ទី១ដែលមានច្រកសាកសពសត្វ

ខ) បិទពីខាងក្រៅថង់ចុងក្រោយ

គ) ក្នុងថង់ចុងក្រោយដែលពុំអាចសើម ឬខូចខាតបាន

### 5.8. យល់ដឹងអំពីគោលការណ៍គ្រឹះ និងសេចក្តីណែនាំសម្រាប់រក្សាប្រព័ន្ធត្រជាក់

តើចំណុចអ្វីដែលជាចំណុចចម្បងបំផុតដែលត្រូវធ្វើ នៅពេលអ្នកយកថង់សំណាក និងសាកសពសត្វត្រឡប់មកប៉ុស្តិ៍វិញ?

ក) ស្រាយថង់ រួចដាក់សំណាកទៅក្នុងថតទូររួចចាក់សោរឲ្យជាប់

ខ) ដាក់ថងរក្សាសំណាក និង/ឬ សាកសពសត្វទៅក្នុងធុងទឹកកកសម្រាប់សត្វ (មិនមែនធុងទឹកកកសម្រាប់ដាក់ម្ហូបអាហារឡើយ)

គ) រក្សាទុកសំណាកនៅក្នុងបន្ទប់ធ្វើការធម្មតា

ឃ) រក្សាទុកសំណាកឲ្យនៅក្តៅៗក្រោមពន្លឺថ្ងៃ